ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១៦៦ ....សហវ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣*

## ជម្រាបជូន

## លោក លោកស្រីជាអគ្គនាយក អគ្គនាយិកា នាយក នាយិកាធនាគារពាណិជ្ជទាំងអស់

**កម្មវត្ថុ:** សំណើអញ្ជើញចូលរួមក្នុងពិធីផ្សព្វផ្សាយឯកសារគោលស្តីពីការចូលរួមផ្តល់សេវាធនាគារពាណិជ្ជ សម្រាប់កិច្ចប្រតិបត្តិការគណនីចំណូល ចំណាយថវិការដ្ឋនៅទូទាំងប្រទេស ក្នុងក្របខ័ណ្ឌគណនីទោល រតនាគារ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់លោក លោកស្រីជាអគ្គនាយក អគ្គនាយិកា នាយក នាយិកាធនាគារពាណិជ្ជទាំងអស់ ជ្រាបថា៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុវត្តសាកល្បងការប្រើប្រាស់សេវាធនាគារពាណិជ្ជសម្រាប់ប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋ ជំហានទី៣ ទទួលបានជោគជ័យ។ ដើម្បីឈានទៅអនុវត្តនៅទូទាំងប្រទេស ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំរួចរាល់នូវឯកសារគោលស្តីពីការចូលរួមផ្តល់សេវាធនាគារពាណិជ្ជសម្រាប់កិច្ចប្រតិបត្តិការគណនីចំណូល ចំណាយថវិការដ្ឋ នៅទូទាំងប្រទេស ក្នុងក្របខ័ណ្ឌគណនីទោល រតនាគារ។

អាស្រ័យហេតុនេះ ធនាគារពាណិជ្ជណាដែលមានបំណងចង់ចូលរួមប្រកួតប្រជែងផ្តល់សេវាធនាគារ សម្រាប់កិច្ចប្រតិបត្តិការគណនីចំណូល ចំណាយថវិការបស់រដ្ឋនៅរាជធានី ខេត្តណាមួយ ឬ នៅទូទាំងប្រទេស សូមអញ្ជើញមកចូលរួមក្នុងពិធីផ្សព្វផ្សាយឯកសារគោលស្តីពីការចូលរួមផ្តល់សេវាធនាគារពាណិជ្ជសម្រាប់កិច្ចប្រតិបត្តិការគណនីចំណូល ចំណាយថវិការដ្ឋនៅទូទាំងប្រទេស ក្នុងក្របខ័ណ្ឌគណនីទោលរតនាគារ ដែលនឹងប្រព្រឹត្តទៅនៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្ងៃព្រហស្បតិ៍ ទី៧ ខែមីនា ឆ្នាំ២០១៣ វេលាម៉ោង៣:០០រសៀល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីជាអគ្គនាយក អគ្គនាយិកា នាយក នាយិកាធនាគារពាណិជ្ជជ្រាប និងអញ្ជើញចូលរួម ឬ ចាត់តំណាងចូលរួមកុំបីខាន។

សូមលោក លោកស្រីជាអគ្គនាយក អគ្គនាយិកា នាយក នាយិកាធនាគារពាណិជ្ជ ទទួលនូវការគោរពរាប់អានយ៉ាងជ្រាលជ្រៅ ពីខ្ញុំ

**អនុរដ្ឋលេខាធិការ** ហត្ថ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត ជូ គឹមខ្លៀង**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com